ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ
លេខ: ៦២២ "ដ" ក្រ៦
ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩
សំណុំរឿងព្រហ្មទណ្ឌលេខ ៧៧៣
ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៩
សំណុំរឿងស៊ើបសួរលេខ ៤០៧
ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ២០១៩
សំណុំរឿងជំនុំជម្រះលេខ ១៥៦៦
ចុះថ្ងៃទី ១០ ខែ ឧសភា ឆ្នាំ២០១៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ វេលាម៉ោង ១៥និង ៣០នាទី រសៀល នៅសាលសវនាការទី៣ ដោយមានសមាសភាព៖

**ចៅក្រមជំនុំជម្រះ**

លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ
លោក [redacted] ចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ
លោក [redacted] ចៅក្រមក្រុមប្រឹក្សាជំនុំជម្រះ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៧៧៣ ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ២០១៩ ដែលមាន ជនជាប់ចោទ៖

-ឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ៤១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនៅ[redacted]ខេត្តពោធិ៍សាត់ ទីលំនៅបច្ចុប្បន្ននៅបន្ទប់ជួល ផ្លូវជាសុផារ៉ា សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ប្តីឈ្មោះ [redacted] ឡុង (លែងលះ) មានកូនបីនាក់ ឪពុកឈ្មោះ [redacted] វ៉ាង "រ" ម្តាយឈ្មោះ [redacted] សូត "រ" ទោសពីមុនធ្លាប់ជាប់មណ្ឌលអប់រំកែប្រែទី២ ចំនួន២ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ជានីតិជន ។ (ដីកាបង្គាប់ឱ្យឃុំខ្លួនលេខ ១០៧៤ (ទ)/ដ.ឃ.ដ ចុះថ្ងៃទី០៣.០២.២០១៩ )

ជាប់ចោទពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ស្រែយើងទល់មុខវត្តនាគវ័ន្ត សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-**មេធាវីការពារជនជាប់ចោទ៖** លោកមេធាវី[redacted] មានការិយាល័យមេធាវីតាព្រហ្ម អាសយដ្ឋានផ្ទះលេខ២៧E1 ផ្លូវលេខ២៥៣ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ២១ និង ២០នាទី កម្លាំងសមត្ថកិច្ច នៃមន្ទីរប្រឆាំងគ្រឿងញៀន បានចុះបង្ក្រាបករណី ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន នៅចំណុចផ្ទះសំណាក់ស្រែយើងទល់មុខវត្តនាគវ័ន្ត សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ បានឃាត់ខ្លួនឈ្មោះ [redacted] ស្រីម៉ៅ ដកហូតវត្ថុតាងម្សៅក្រាមពណ៌ដែលមានទម្ងន់ ២៥,៤០ក្រាម (ម្ភៃប្រាំក្បៀសសែសិបក្រាម) និងទូរស័ព្ទចំនួន ០១គ្រឿង រួចសមត្ថកិច្ចបានកសាងសំណុំរឿង បញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធីច្បាប់។

-បានឃើញ របាយការណ៍លេខ ៣៤៦/១៩ រ.ប.ក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀន នៃក្រសួងមហាផ្ទៃ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ៤៣៩ អ.ឃ.ឯ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្តាពរលេខ ១៥៥៤ អ.ឃ.ឯ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការ អម សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២០៥៩ "អ" ដ.ដ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ បានឆ្លើយសារភាពថា៖ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ វេលាម៉ោងប្រហែល ១៨ និង ១០នាទី ខ្លួនបានទិញថ្នាំញៀនប្រភេទក្រាមទឹកកកពីឈ្មោះ ញ៉ា ក្នុងតំលៃ ៥០០$ ដើម្បីយកទៅលក់បន្តឲ្យមនុស្ស ប្រុសម្នាក់ដែលបាន បញ្ជាទិញពីខ្លួន។ បន្ទាប់ពីទិញថ្នាំញៀនពីឈ្មោះ ញ៉ា បានហើយ ខ្លួនបានយកថ្នាំញៀននោះទៅលក់បន្ត អោយអ្នកដែលបានបញ្ជាទិញពីខ្លួន ក្នុងតំលៃ ៥៨០ ដុល្លាអាមេរិក ដោយណាត់ជួបគ្នាក្នុងផ្ទះសំណាក់ស្រែយើង ម្តុំវត្តនាគវ័ន្ត ប៉ុន្តែពុំទាន់បានជួបអ្នកទិញផង ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

## សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនាការ និងពិនិត្យភស្តុតាងក្នុងសំណុំរឿងឃើញថា ជនជាប់ចោទបានឆ្លើយសារភាពថា ខ្លួនពិតជាបានទិញថ្នាំញៀន យកទៅលក់បន្តដើម្បីយកប្រាក់ចំណេញប្រាកដមែន ដូចនេះបញ្ជាក់ឲ្យឃើញថា ជនជាប់ចោទពិតជាបានប្រព្រឹត្ត អំពើ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន ។ ក្នុងនាមខ្ញុំជាតំណាងអយ្យការ ខ្ញុំនៅតែរក្សាបទចោទប្រកាន់ ដូចមានក្នុងដីកាសន្និដ្ឋានស្តាពរលេខ ១៥៥៤ អ.ឃ.ឯ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការអម សាលា ដំបូងរាជធានីភ្នំពេញ ទុកជាបានការដដែល និងប្តឹងសុំឱ្យតុលាការសម្រេចទៅតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-លោក [redacted] មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ឆ្លងតាមការសួរដេញដោលនាពេលសវនការ និងការពិនិត្យឯកសារនានាក្នុងសំណុំរឿងឃើញថា៖ កូនក្តីខ្លួនបានឆ្លើយ សារភាពគ្រប់ដំណាក់ដែលនេះបញ្ជាក់ថាកូនក្តីខ្លួនបានដឹងអំពីកំហុសដែលបានប្រព្រឹត្ត ម្យ៉ាងទៀតមូលហេតុដែលកូនក្តីខ្លួន ប្រព្រឹត្តអំពើជួញដូរថ្នាំញៀនព្រោះតែមានជីវភាពក្រីក្រ និងត្រូវការថវិកា ហើយមានការសិក្សាអប់រំទាប ដូចនេះក្នុងនាម ខ្លួនជាមេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ ស្នើសុំឱ្យតុលាការពិចារណាទៅលើស្ថានសម្រាលទោស ដល់កូនក្តីខ្លួនផង។

## សម្តីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ បាននិយាយតំរង់ចុងក្រោយថា: សុំឱ្យតុលាការបន្ធូរបន្ថយទោសដល់ខ្លួនផង ។

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធជនជាប់ចោទ

-ក្រោយពីបានស្តាប់ជនជាប់ចោទនិយាយសំដីចុងក្រោយ

-ក្រោយពីពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

០១-ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ២០៥៩ "អ" ដ.ដ ចុះថ្ងៃទី០៦ ខែឧសភា ឆ្នាំ២០១៩ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ និងដីកាសន្និដ្ឋានស្តាពរលេខ ១៥៥៤ អ.យ.ឯ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ បានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ ពីបទ៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ស្រែយើងទល់មុខវត្តនាគវ័ន្ត សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

០២-ជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ បានឆ្លើយសារភាពថា៖ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ប្រហែល ១៨ និង ១០នាទី ខ្លួនបានទិញថ្នាំញៀនប្រភេទក្រាមទឹកកកពីឈ្មោះ ញ៉ា ក្នុងតំលៃ ៥០០$ ដើម្បីយកទៅលក់បន្ត ឱ្យមនុស្សប្រុសម្នាក់ដែលបានបញ្ជាទិញពីខ្លួន។ បន្ទាប់ពីទិញថ្នាំញៀនពីឈ្មោះ ញ៉ា បានហើយ ខ្លួនបានយកថ្នាំញៀននោះទៅលក់បន្ត អោយអ្នកដែលបានបញ្ជាទិញពីខ្លួន ក្នុងតំលៃ ៥៨០ ដុល្លារអាមេរិក ដោយណាត់ជួបគ្នាក្នុងផ្ទះសំណាក់ស្រែយើងម្តុំវត្តនាគវ័ន្ត ប៉ុន្តែពុំទាន់បានជួបអ្នកទិញផង ក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួនតែម្តង។

០៣- តាមរបាយការណ៍លេខ ៣៤៦/១៩ រ.ប.ក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ បានបញ្ជាក់ថា កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ វេលាម៉ោង ប្រហែល ១៨ និង ១០នាទី មានករណីជួញដូរដោយ ខុសច្បាប់កើតឡើងនៅចំនុចផ្ទះសំណាក់ស្រែយើងទល់មុខវត្តនាគវ័ន្ត សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ បង្កឡើងដោយឈ្មោះ [redacted] ស្រីម៉ៅ។

០៤- តាមចម្លើយសារភាពរបស់ជនជាប់ចោទ មានភាពស៊ីសង្វាក់គ្នាទៅនឹង ភស្តុតាងផ្សេងរួមទាំងរបាយការណ៍របស់មន្ទីរប្រឆាំងគ្រឿងញៀននៃក្រសួងមហាផ្ទៃ អាចឱ្យតុលាការជឿជាក់ថាជនជាប់ចោទពិតជាបានប្រព្រឹត្ត ដូចការចោទប្រកាន់ច្រាកដមែន។

០៥- អំពើរបស់ជនជាប់ចោទ ដែលបានទិញគ្រឿងញៀនយកទៅលក់បន្តឱ្យអ្នកដទៃ ដើម្បីទទួលបានផលចំណេញ ជាបទល្មើស **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** ជាបទល្មើសព្រហ្មទណ្ឌ ដែលតម្រូវឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

០៦- អំពើ និងសកម្មភាពរបស់ជនជាប់ចោទ ធ្វើឱ្យខូចសណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងប៉ះពាល់ដល់សុខភាព និងសតិបញ្ញាស្មារតី របស់ប្រជាពលរដ្ឋទូទៅដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។

០៧- ពេលធ្វើសកម្មភាពជនជាប់ចោទ មានសតិស្មារតីគ្រប់គ្រាន់ ប្រព្រឹត្តអំពើល្មើសច្បាប់រហូតសម្រេចបំណងរបស់ខ្លួន ហើយជានីតិជនដែលមានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើ របស់ខ្លួនដែលបានប្រព្រឹត្ត។

០៨- តាមលទ្ធផលកោសលវិច័យគ្រឿងញៀនលេខ ១៧៨៨៨/១៩ ម.ព.អ.ជ.ប.ត.ញ ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់មន្ទីរពិសោធ៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលទ្ធផលបញ្ជាក់ថា

សំណាកជាគ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក), ដែលមានកម្រិតភាពសុទ្ធ ៨០,៣៩% (ប៉ែតសិបក្បៀសសាមសិបប្រាំបួនភាគរយ) នៃទម្ងន់សរុប, វាស្ថិតក្នុង តារាងទី២ មាត្រា៥ ចំណាត់ថ្នាក់គ្រឿងញៀនដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

០៩- តាមការគណនាអំពីភាពសុទ្ធនៃមេតំហ្វេតាមីន របស់ជនជាប់ចោទឈ្មោះ [redacted] ស្រីម៉ៅ មានទម្ងន់សរុប ២៥.៤០ (ម្ភៃប្រាំកណ្តាក់សញ្ញាសែសិប)ក្រាម ដែល (២៥.៤០ក្រាម x ៨០,៣៩)/១០០ ឃើញថាបរិមាណនៃភាពសុទ្ធមាន ចំនួន ២០,៤១ (ម្ភៃក្បៀសសញ្ញាសែសិបមួយ)ក្រាម។

លទ្ធផល ២០,៤១ ក្រាម គឺស្ថិតក្នុងតារាងទី២ នៃមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលតម្រូវឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ទៅ ១០(ដប់)ឆ្នាំ និងអាចទទួលបន្ថែមនូវទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន)រៀល ទៅ២០.០០០.០០០ (ម្ភៃលាន)រៀល ហេតុនេះ គប្បីតុលាការពិចារណាអំពីការផ្តន្ទាទោសសម្រាប់ ជនជាប់ចោទនេះ។

១០- មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ស្រីម៉ៅ ពីបទ៖ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ស្រែយើងទល់មុខវត្តនាគវ័ន្ត សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩។

១១- តំណាងអយ្យការប្តឹងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ដែលចំណុចនេះគប្បីតុលាការ ពិចារណាសុំអោយតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទ តាមផ្លូវច្បាប់ និង រក្សាបទចោទដូចមានក្នុងដីកាសន្និដ្ឋានស្តាពរលេខ ១៥៥៤ អ.យ.ង ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ។

១២- កំណត់ហេតុទទួលវត្ថុចាប់យកលេខ ៣៥៣ រ.វ.ត ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១៩ មាន៖

-ស្រោមសំបុត្របិទជិតពណ៌គគីដែលមានសរសេរថា ក្រាមពណ៌សផ្ទាទម្ងន់ ២៥.៤០ (ម្ភៃប្រាំកណ្តាក់សញ្ញាសែសិប) ក្រាម ដែលមានផ្តិតស្នាមមេដៃរបស់ជនឈ្មោះ [redacted] ស្រីម៉ៅ និងចូលរួមចុះហត្ថលេខា និងត្រាពីមន្ត្រីនគរបាលយុត្តិធម៌។

-ទូរស័ព្ទដៃចំនួន០១គ្រឿង ម៉ាក I-mobile។

ជាវត្ថុតាង នៃ ការប្រព្រឹត្តបទឈ្មើសគប្បីតុលាការ សម្រេចរឹបអូស តាមបញ្ញត្តិមាត្រា ៩៣ និង៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

## ហេតុដូច្នេះសម្រេច

១.ផ្តន្ទាទោស៖ ឈ្មោះ [redacted] ស្រីម៉ៅ ភេទស្រី អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ចំនួន ០៥ឆ្នាំ (ប្រាំឆ្នាំ) និងពិន័យជាប្រាក់ចំនួន ១០,០០០,០០០៛ (ដប់លានរៀល) ពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចផ្ទះសំណាក់ស្រែយើងទល់មុខវត្តនាគវ័ន្ត សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាលពីថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៩ តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. វត្ថុចាប់យកមាន៖

២.១. ស្រោមសំបុត្រពណ៌គគីចំនួន០១ និងថ្នាំញៀនប្រភេទមេតំហ្វេតាមីន (ហៅក្រៅអាយ ឬម៉ាទឹកកក) ទម្ងន់ ២៥.៤០ (ម្ភៃប្រាំកណ្តាក់សញ្ញាសែសិប) ក្រាម។

២.២.ទូរស័ព្ទដៃចំនួន០១គ្រឿង ម៉ាក I-mobile។

សម្រេចរឹបអូសចូលរដ្ឋ តាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៩ ចំពោះមុខជនជាប់ចោទ, មេធាវីការពារសិទ្ធិជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៩ ។

ទុកសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | | | |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃពុធ ១៤កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញថ្ងៃ,ទី១៤ ខែសីហា ឆ្នាំ២០១៩

ក្រឡាបញ្ជី

[redacted]

បានឃើញ

ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]